# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ២៤៣៤ "ឈ១"

ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤៧

ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០

សំណុំរឿងជំនុំជម្រះលេខ ៣២៥៦

ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៤ និង ៣០នាទី រសៀល នៅសាលសវនាការទី១ ដែលមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី **ឌិត ដាលីន** ចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក **សាយ ណារ៉ា** ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក **ឈិន ឆេង** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៤៨៤៧ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ:

១-ឈ្មោះ **គង់ ហេង** ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ កាន់សាសនា ព្រះពុទ្ធ មុខរបរ៖ អនុប្រធានគ្រប់គ្រងផ្នែកទីផ្សាររបស់ក្រុមហ៊ុន VINITON GROUP CO.,LTD មានទីកន្លែងកំណើតនៅភូមិកំពង់បាយ សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៧ ផ្លូវលេខ១ បុរីពិភពថ្មីទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ហុក ម៉េង** "ស្លាប់" ម្តាយឈ្មោះ **នាង ហៀង** "ស្លាប់" ប្រពន្ធឈ្មោះ **តា ជាសុខលី** មានកូនចំនួន០៣នាក់ ជានីតិជន ទោសពីមុន "គ្មាន" (ក្រៅឃុំ)។

២-ក្រុមហ៊ុន VINITON GROUP CO.,LTD មានអាសយដ្ឋានចុះបញ្ជីនៅផ្ទះលេខ៦ ផ្លូវលេខ៤១៦ ភូមិ១ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

-មានលោកមេធាវី **ថេង វិបុល** អត្តលេខ១៧៥៧ ,លោកស្រីមេធាវី **គង់ សុចិត្ត** អត្តលេខ៧៧៨ ,លោកស្រីមេធាវី **អឿ សុងលីនដា** អត្តលេខ២២១៥T មានការិយាល័យនៅអូវលលេខ ១៦-១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឲ្យក្រុមហ៊ុន VINITON GROUP CO.,LTD។

-មានលោកមេធាវី **ហ៊ីង សៅលិញ** អត្តលេខ១២៣៩ មានការិយាល័យនៅផ្ទះលេខ៥៧+៥៩ ផ្លូវបេតុង ក្រុមទី៣ ភូមិទ្រា៤ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យក្រុមហ៊ុន VINITON GROUP CO.,LTD។

ជាប់ចោទពីបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ០៩ ,មាត្រា ១០ ,មាត្រា ១១ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

-ដើមបណ្តឹងរដ្ឋប្បវេណី ក្រសួងសុខាភិបាល មានអាយដ្ឋាននៅដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ តំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ុង ភីរុន** ជារដ្ឋលេខាធិការក្រសួងសុខាភិបាល។

-មានលោកមេធាវី **លឹម ស៊ីម** អត្តលេខ៥៩១ ,លោកមេធាវី **ខៀវ វ៉ាន** អត្តលេខ៣៧៤ ,លោកមេធាវី **កឹម វឌ្ឍនៈ** អត្តលេខ១៨៨៦T និងលោកមេធាវី **សែម ស៊ីនវិទ្ធ** អត្តលេខ១៨៨៣T មានការិយាល័យនៅបន្ទប់លេខ៤២ ,២៣F អគារ The Bridge-SOHO ផ្លូវរដ្ឋសភាជាតិ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឱ្យក្រសួងសុខាភិបាល។

## អង្គហេតុនៃរឿងមានដូចតទៅ

កន្លងមកភ្នាក់ងាររបស់ក្រុមហ៊ុន VINITON Group Co.,Ltd ដែលជាក្រុមហ៊ុនលក់ផលិតថ្នាំជក់បានធ្វើការផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួននៅទីសាធារណៈ ជាលក្ខណៈផ្ទាំងរូបភាពពាណិជ្ជកម្មនៃផលិតផលថ្នាំជក់។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុននេះបានធ្វើការលើកកម្ពស់ផ្សព្វផ្សាយផលិតផលថ្នាំជក់ដល់អតិថិជន ដោយប្រើពាក្យទាក់ទាញ និងធ្វើឱ្យយល់ច្រលំ ហើយឱ្យបុគ្គលិកចុះទៅផ្សព្វផ្សាយតាមភោជនីយដ្ឋាន និងទីសាធារណៈ ដែលជាសកម្មភាពត្រូវបានហាមឃាត់ក្នុងការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់។ ម្យ៉ាងវិញទៀត ក្រុមហ៊ុននេះបានប្រើពាក្យទាក់ទាញ និងធ្វើឱ្យយល់ច្រលំ ដូចជារក្សាក្លិន និងគុណភាពបានល្អថែមទៀត។ នៅក្នុងឆ្នាំ២០១៩ ឆ្នាំ២០២០ ភ្នាក់ងារមានសមត្ថកិច្ចបានថតយកនូវរូបភាពមួយចំនួនពាក់ព័ន្ធនឹងការផ្សព្វផ្សាយជាសាធារណៈនូវផលិតផលថ្នាំជក់របស់ក្រុមហ៊ុន VINITON ដោយពុំអនុលោមតាមបទបញ្ញត្តិច្បាប់ និងបានធ្វើសេចក្តីប្តឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល តំណាងដោយឯកឧត្តមវេជ្ជបណ្ឌិត **អ៊ុង ភីរុន**។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ០៨៤ អ.យ.ន ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌរបៀបលេខ ១៦៣ “ឈ១” ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: **០៥៨ អ.យ.ឃ** ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **គង់ ហេង** បានឆ្លើយថា: ពាក់ព័ន្ធនឹងរូបភាពដែលលោកស្រីចៅក្រមបង្ហាញនេះដូចហេតុផលដែលខ្ញុំបានជម្រាបអញ្ចើង រូបនេះគឺក្រុមហ៊ុនបានចែកចាយជាយូរណាស់មកហើយ ហើយក្រុមហ៊ុនកំពុងតែដើរប្រមូលយករូបនេះទាំងអស់នេះមកវិញ ដើម្បីធ្វើការបំផ្លាញចោល តែវានៅសល់ខ្លះៗនៅលើទីផ្សារ តែក្រុមហ៊ុនក៏ព្យាយាមប្រមូលយកមកទាំងអស់។ កន្លងមកក្រុមហ៊ុនបានព្យាយាមសុំជួបខាងក្រសួងសុខាភិបាល ដើម្បីសូមទោសពីកំហុសទាំងនេះ និងសូមធ្វើការណែនាំ ប៉ុន្តែខាងក្រសួងមិនព្រមឲ្យជួបនោះទេ។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ខាងក្រុមហ៊ុនបានជួបជាមួយក្រសួងសេដ្ឋកិច្ច និងក្រសួងសុខាភិបាល និងបានបកប្រាយជូនក្រសួងសុខាភិបាលពាក់ព័ន្ធនឹងរូបភាព ដែលក្រុមហ៊ុនបានចែកចាយជាយូរមកហើយនោះ ។ ក្រុមហ៊ុន VINITON មានបារីច្រើនប្រភេទ ប៉ុន្តែមានបារីខ្លះយើងបានចរាចរ ហើយបារីខ្លះមិនទាន់បានចរាចរទេ ចំពោះបារីដែលចរាចរណ៍លើកទីផ្សារនៅកម្ពុជាមានប្រាំប្រភេទ មានបារីក្រោន បារីអង្គរ បារីខេមបូ បារីលុចសារី និងបារីអង្គរលុចសារី។ ក្រោយពេលទទួលបានដំណឹងពីក្រសួងសុខាភិបាលមក ក្រុមហ៊ុនបានព្យាយាមសុំជួបខាងក្រសួងខាភិបាល និងបានពន្យល់អំពីរឿងហេតុនេះ ប៉ុន្តែខាងក្រសួងព្រមឲ្យជួបនោះទេ ហើយក៏មិនឃើញមានការឆ្លើយតបអ្វីពីក្រសួងដែរ។ ខ្ញុំសូមបញ្ជាក់ថា ក្រោយពីទទួលដំណឹងពីខាងក្រសួងសុខាភិបាលពីករណីរឿងរូបភាពនេះ ខាងក្រុមហ៊ុនបានព្យាយាមប្រមូលយករូបភាពទាំងអស់មកវិញ ប៉ុន្តែជាធម្មតាយើងមិនអាចប្រមូលបានយកមកវិញទាំងអស់ទេ ប៉ុន្តែកន្លងមកមានអាជ្ញាធរបានធ្វើការណែនាំរួចហើយ។ តាំងពីពេលកើតហេតុមក ក្រុមហ៊ុនមិនបានចេតនាក្នុងការផ្សព្វផ្សាយទៀតទេ។ ក្រុមហ៊ុនមិនដែលបានទទួលលិខិតព្រមានជាលាយល័ក្ខណ៍អក្សរពីខាងក្រសួងនោះទេ ប៉ុន្តែក្រុមហ៊ុនទទួលបានព័ត៌មានខ្លះៗដែរ។ មុនពេលដែលបារីដាក់លក់លើទីផ្សារ ខាងក្រុមហ៊ុនមានគណៈកម្មការមួយដែលមានសមាជិកពី០៦ ទៅ១២នាក់ មានសមាជិកក្រុមហ៊ុនប្រឹក្សាភិបាល និងផ្នែកទីផ្សារ ដែលប្រធានគណៈកម្មការមានតួនាទីជាប្រធានក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យ ។

-ក្រឡាបញ្ជីអានពាក្យបណ្ដឹងរបស់ក្រសួងសុខាភិបាល ដែលតំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត អ៊ឹង ភីរុន ជារដ្ឋលេខាធិការក្រសួងសុខាភិបាល បានបញ្ជាក់ថា: កន្លងមកក្រុមហ៊ុន VINITON Group Co,Ltd ដែលជាក្រុមហ៊ុនលក់ផលិតផលថ្នាំជក់ បានធ្វើការផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួននៅទីសាធារណៈជាលក្ខណៈផ្ទាំងគំនូរ និងប័ណ្ណផ្សព្វផ្សាយ ហើយក្នុងនោះក្រុមហ៊ុននេះបានប្រើប្រាស់ពាក្យទាក់ទាញ និងធ្វើឲ្យយល់ច្រលំដូចជាពាក្យថា ដើមតូច គ្រាប់តូច រស់ជាតិផ្លែឈើ ក្លិនក្រអូប ស្រទន់ជាដើម ដូចមានបញ្ជាក់ក្នុងរូបភាពដែលភ្ជាប់ជាមួយភស្តុតាង។ ក្រសួងសុខាភិបាលក៏បានធ្វើការព្រមានក្រុមហ៊ុននេះរួចហើយដែរ អំពីសកម្មភាពខាងលើ ព្រោះថាវាជាសកម្មភាពខុសច្បាប់ ប៉ុន្តែក្រុមហ៊ុននេះនៅតែមិនគោរពតាមច្បាប់ និងការ

ព្រមានរបស់ក្រសួងសុខាភិបាលទៀត។ យោងតាមសកម្មភាពខាងលើ គឺក្រុមហ៊ុននេះបានបំពាននូវច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ហើយការផ្សព្វផ្សាយបែបនេះអាចជម្រុញឲ្យមានការប្រើប្រាស់ថ្នាំជក់កាន់តែច្រើន និងអាចនាំឲ្យមានផលប៉ះពាល់ដល់សុខភាពប្រជាជន និងសុខភាពសាធារណៈដែលច្បាប់ព្យាយាមការពារ ។

-លោក **ខៀវ វ៉ា** ,លោក **លឹម ស៊ីម** ,លោក **សែម ស៊ីនរិទ្ធ** និងលោក **គឹម វឌ្ឍនៈ** ជាមេធាវីតំណាងឲ្យក្រសួងសុខាភិបាល បានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង ឃើញថា ក្រសួងសុខាភិបាលបានប្តឹងទៅលើក្រុមហ៊ុន VINITON GROUP CO.,LTD ដែលគាត់បានប្រព្រឹត្តសកម្មភាពកាលពីអំឡុងឆ្នាំ២០១៩-២០២០ ទៅលើសកម្មភាពជាច្រើនពាក់ព័ន្ធនឹងផ្សព្វ ផ្សាយផលិតផលថ្នាំជក់របស់ខ្លួនជាសាធារណៈ ដោយបានប្រើប្រាស់នូវពាក្យទាក់ទាញដែលធ្វើឲ្យមានការយល់ច្រលំដូចជា ដើមតូច គ្រាប់ចុច រស់ជាតិផ្លែឈើ ក្លិនក្រអូបស្រទន់ ជាដើម ហើយក្រសួងសុខាភិបាលក៏បានធ្វើការព្រមានទៅក្រុមហ៊ុនអំពីសកម្មភាពខាងលើថាជាកម្មភាពខុសច្បាប់ ប៉ុន្តែក្រុមហ៊ុននៅតែមិនគោរពច្បាប់ និងមិនទទួលយកការព្រមានរបស់ក្រសួងសុខាភិបាលទៀតផង នៅក្នុងនេះគាត់បានប្រព្រឹត្តជាច្រើនខុសពីច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។ សូមបញ្ជាក់ថា ពាក់ព័ន្ធជាមួយនឹងការលើកឡើងរបស់តំណាងក្រុមហ៊ុន ករណីដែលគាត់ថាការផ្សព្វផ្សាយពាណិជ្ជកម្មដែលបុគ្គលិកគាត់ធ្វើដោយចិត្តឯងនោះ គឺមិនត្រឹមត្រូវទេ ពីព្រោះបុគ្គលិករបស់ក្រុមហ៊ុនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ស្ថិតនៅក្រោមការបញ្ជារបស់ក្រុមហ៊ុន អញ្ចឹងមិនមានបុគ្គលិកណាមានសិទ្ធិដែលត្រូវធ្វើការការជំនួសក្រុមហ៊ុនទេ មិនអាចសម្រេចជំនួសក្រុមហ៊ុនបានទេ អញ្ចឹងក្រុមហ៊ុនត្រូវតែទទួលខុសត្រូវរាល់សកម្មភាពទាំងឡាយណា ដែលកើតឡើងដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន។ ចំពោះភស្តុតាងមានការបោះពុម្ព ស្ទីកឃើរ ជាទូទៅគឺក្រុមហ៊ុនជាអ្នកផលិត ជាអ្នកចែកចាយឲ្យអ្នកលក់មិនគិតថ្លៃ ជាការលើកទឹកចិត្តដល់អ្នកលក់ ដើម្បីឲ្យគាត់ប្រឹងលក់ ហើយជាពិសេសតាមទូលក់បារី អានឹងហើយដែលជាកម្មភាពបង្ហាញនូវការលើកទឹកចិត្ត និងជំរុញឲ្យមានការប្រើប្រាស់បារីដែលត្រូវបានច្បាប់ហាមឃាត់។ ចំពោះសកម្មភាពបទល្មើសដែលក្រុមហ៊ុនបានប្រព្រឹត្ត គឺច្បាប់បានចេញមុនសកម្មភាពរបស់ក្រុមហ៊ុន រួចហើយក្រោយពេលដែលច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ចេញរួចខាងក្រសួងសុខាភិបាលបានធ្វើការជូនដំណឹងទៅឲ្យខាងក្រុមហ៊ុន ដើម្បីឲ្យក្រុមហ៊ុនអនុវត្តតាមច្បាប់ ។ ប៉ុន្តែក្រុមហ៊ុនអនុវត្តទេ ជាក់ស្តែងដូចភស្តុតាងដែលខ្ញុំបាទបានដាក់ជូនតុលាការស្រាប់ គឺក្រសួងបានធ្វើការជូនដំណឹងទៅក្រុមហ៊ុន០៣ដង ជាការព្រមានសុំឲ្យបញ្ឈប់សកម្មភាពផ្សេងៗទាំងឡាយណាដែលផ្ទុយនឹងច្បាប់ដូចមានចែងក្នុងមាត្រាច្បាប់ ប៉ុន្តែក្រុមហ៊ុនមិនស្តាប់ទាល់តែសោះ ដែលនេះជាសកម្មភាពល្មើសច្បាប់ ទោះបីគាត់អះអាងយ៉ាងណាក៏ដោយ ប៉ុន្តែសកម្មភាពបានកើតឡើងរួចទៅហើយ បទល្មើសបានកើតឡើងរួចទៅហើយ ហើយខាងក្រុមហ៊ុនក៏មិនព្រមធ្វើកិច្ចសន្យាបញ្ឈប់នោះដែរ ហេតុនេះហើយ ក្នុងនាមខាងក្រសួងសុខាភិបាលស្នើសុំឲ្យតុលាការមេត្តាពិចារណា និងសំណូមពរសុំឲ្យតុលាការផ្តន្ទាទោសទៅលើក្រុមហ៊ុន VINITON និងអ្នក

តំណាង ព្រមទាំងបក្ខពួក តាមច្បាប់ឲ្យបានធ្ងន់ធ្ងរ ,ទាមទារសំណងជំងឺចិត្តចំនួន ៤០លានរៀល ចូលជាថវិការដ្ឋ , សុំផ្តន្ទាទោសបន្ថែមលើក្រុមហ៊ុន VINITON តាមមាត្រា ៤៧ ចំណុច៣ ចំណុច៤ និងចំណុច៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា និងការពិនិត្យភស្តុតាង ឃើញថា កាលពីអំឡុងឆ្នាំ២០១៩-២០២០ ក្រុមហ៊ុន VINITON បានធ្វើការផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួនដោយប្រើពាក្យទាក់ទាញដែលធ្វើឲ្យមានការយល់ច្រលំដូចជា ដើមតូចគ្រាប់ចុច រស់ជាតិផ្លែឈើ ហើយខាងក្រសួងក៏បានធ្វើការព្រមានពីផលប៉ះពាល់ដែរ ប៉ុន្តែខាងក្រុមហ៊ុនមិនស្តាប់នោះទេ។ ក្នុងនាមតំណាងអយ្យការ សុំតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ០៥៨ អ.យ.យ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ ទុកនៅដដែល និងសុំឲ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-លោកស្រី **អឿ សុងលីនដា** និងលោក **ហ៊ីង សៅលិញ** ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ គង់ ហេង និងក្រុមហ៊ុន VINITON GROUP CO.,LTD បានធ្វើសេចក្តីសន្និដ្ឋានថា: ក្រុមហ៊ុន VINITON GROUP CO.,LTD គឺជាក្រុមហ៊ុនផលិត និងលក់ផលិតផលថ្នាំជក់ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ១៩៩៣ មកម្ល៉េះ។ ក្រុមហ៊ុនបានខិតខំព្យាយាមស្វែងយល់ និងអនុវត្តកាតព្វកិច្ចស្របទៅតាមច្បាប់ដែលមានជាធរមាន រាប់បញ្ចូលទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់។ ក្នុងរយៈពេលជិត ០៣ ទស្សវត្ស កន្លងមកនេះ ក្រុមហ៊ុនអនុវត្តជាប្រចាំយ៉ាងត្រឹមត្រូវ និងមិនដែលបង្កឲ្យមានកំហុសឆ្គងណាមួយឡើយ។ ស្រាប់តែក្នុងខែកក្កដា ឆ្នាំ២០២០ ខណៈដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែជួបវិបត្តិធ្ងន់ធ្ងរ នៃជំងឺសកលផងដែរ ក្រសួងសុខាភិបាលបន្ថែមបន្ទុកធ្ងន់មួយទៀត គឺបានដាក់ពាក្យបណ្តឹងមកក្រុមហ៊ុនថ្នាំជក់មួយចំនួន រួមទាំងក្រុមហ៊ុនយើងខ្ញុំផង ពីបទ ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអស់ពីក្រសួងសុខាភិបាល។ បន្ទាប់ពីទទួលបានដំណឹងពីបណ្តឹងរបស់ក្រលងសុខាភិបាលក្នុងមុងខែកុម្ភៈ ឆ្នាំ២០២១ រយៈដីកាកោះ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមហ៊ុនយើងខ្ញុំមានការចាប់ផ្អើលយ៉ាងខ្លាំង នឹងបានរួសរាន់ធ្វើលិខិតសំណើសុំជួបតំណាងក្រសួងសុខាភិបាល (លិខិតចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១) អំពីបញ្ហាជុំវិញនៃបណ្តឹង និងស្នើសុំដំបូន្មានអំពីការកែតម្រូវចំណុចខ្វះខាត ប៉ុន្តែក្រសួងពុំទទួលការណាត់ជួបឡើយ ។

**ភស្តុតាងដាក់បន្ទុក:** រូបភាពចំនួន០៤ទំព័រ ដូចមានភ្ជាប់ក្នុងពាក្យបណ្តឹង ជារូបភាពដែលគ្មានកាលបរិច្ឆេទ និងជារូបភាពពុំមានភស្តុតាងច្បាស់លាស់អំពីបុគ្គលដែលធ្វើការផ្សព្វផ្សាយ ឬម្ចាស់ខិតប័ណ្ណរបស់ក្រុមហ៊ុនណាមួយ ឬរបស់បុគ្គលណាមួយឱ្យច្បាស់លាស់នោះទេ។ ក្នុងនោះមានរូបភាព០១សន្លឹក ដែលបានសរសេរថា "កម្មវិធីប្រកួតប្រជែងតាំងផលិតផល" គឺជាការផ្សព្វផ្សាយរបស់ភ្នាក់ងារចែកចាយក្នុងបណ្តាញទំនាក់ទំនងសង្គម ដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុនកូនក្តីយើងខ្ញុំឡើយ ហើយក្រុមហ៊ុនកូនក្តីយើងខ្ញុំបានបញ្ឈប់ទំនាក់ទំនងជាភ្នាក់ងារចែកចាយរូបនេះផងដែរ។ រូបភាពខាងលើ ក្រុមហ៊ុនកូនក្តីយើងខ្ញុំបានឈប់ប្រើប្រាស់យូរមក

ហើយ។ ចំណែករូបភាពផ្សេងទៀត គឺជារូបភាពចាស់ដែលក្រុមហ៊ុនដែលជាកូនរបស់យើងខ្ញុំបានធ្វើការប្រមែប្រមូលមកកំទេចចោលអស់រួចមកហើយ ប៉ុន្តែនៅមានរូបភាពមួយចំនួនដែលភ្នាក់ងារចែកចាយបានរក្សាទុកដោយមិនពាក់ព័ន្ធនឹងក្រុមហ៊ុនហើយនោះទេ ហើយក្រុមហ៊ុនក៏មិនបានដឹងថារូបភាពទាំងនេះនៅសេសសល់ដែរ។

**ភស្តុតាងដោះបន្ទុក:** លិខិតចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ អំពីការស្នើសុំសម្របសម្រួលទទួលការពិន័យ និងសុំដំបូន្មានអំពីការតម្រូវឲ្យត្រូវតាមបទដ្ឋានគតិយុត្តិនានា ប៉ុន្តែត្រូវបានតំណាងរបស់ក្រសួងសុខាភិបាលដែលមានឧត្តមវេជ្ជបណ្ឌិត **អ៊ឹង ភិរុន** បដិសេធអំពីការណាត់ជួប និងផ្តល់ដំបូន្មានក្នុងនាមក្រសួងជាអាណាព្យាបាល មកកាន់កូនក្តីយើងខ្ញុំដែលតែងតែអនុលោមតាមច្បាប់ និងការណែនាំរបស់ក្រសួង។ ក្រសួងសុខាភិបាលពុំបានអនុវត្តជូនលិខិតជូនដំណឹងអំពីករណីខាងលើជាមុន ឬបញ្ជូននូវលិខិតសារព្រមានជូនក្រុមហ៊ុនកូនក្តីយើងខ្ញុំឡើយ ហើយក៏ពុំបានទុកឱកាសនាវាទសម្រាប់បញ្ឈប់សកម្មភាពផងដែរ នេះជាការធ្វើរំលងនៃនីតិវិធីច្បាប់ជាធរមាន ហើយជាការបង្កប់នូវការអនុវត្តដោយលំអៀង។

**អង្គច្បាប់:** ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ០៨៤ អ.យ.ន ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៩ ,មាត្រា ១១ ,មាត្រា ៣៩ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ គឺស្ថិតក្នុងករណីអំពើល្មើសលហុ ដែលត្រូវផាកពិន័យជាប្រាក់ ដែលត្រូវយកមកផ្តន្ទាទោសលើបុគ្គល ឬនីតិបុគ្គល ដែលមានចេតនារឹងរុះ ពុំព្រមទទួលយកការផាកពិន័យដោយស្ម័គ្រចិត្ត និងជាជម្រើសចុងក្រោយរបស់ក្រសួងសុខាភិបាល។ មានន័យថា ត្រូវតែអនុវត្តតាមជំហ៊ានបួនឲ្យបានចប់សព្វគ្រប់សិន ដូចជាជូនដំណឹងឲ្យបញ្ឈប់ការផ្សព្វផ្សាយ ជូនដំណឹងព្រមាន ជូនដំណឹងអំពីការដកហូតសម្ភារៈល្មើស ជាដើម-ល- ស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្ម ផលិតផលថ្នាំជក់។ ការដាក់ទណ្ឌកម្មអំពីកំហុសនៃការផ្សព្វផ្សាយ ត្រូវបានអនុវត្តជាជំហ៊ានស្របតាមមាត្រា ១០ នៃអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ ដែលបានចែងថា ក្រុមហ៊ុនថ្នាំជក់ ផលិតករក្នុងស្រុក អ្នកនាំចូលផលិតផលថ្នាំជក់ អាជីវករ អ្នកពាក់ព័ន្ធនឹងការផ្សព្វផ្សាយ និងអ្នកចែកចាយផលិតថ្នាំជក់ ដែលមិនគោរពបទប្បញ្ញតិនៃអនុក្រឹត្យនេះត្រូវទទួលទណ្ឌកម្ម ដូចតទៅ៖ -ព្រមានជាលាយលក្ខណ៍អក្សរ -ដកហូតផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬប័ណ្ណផ្សព្វផ្សាយផលិតផលថ្នាំជក់ផ្សេងៗទៀត ....។ ក្នុងន័យនេះក្រសួងពុំបានអនុវត្តតាមដំណាក់កាលនៃអនុវត្តនីតិវិធីនោះទេ ដោយពុំបានអនុវត្តចំណុចទី១ គឺព្រមានជាលាយលក្ខណ៍អក្សរ ឬកំណត់ឱកាសនាវាទសម្រាប់កែតម្រូវ-ដកចេញ និងអនុវត្តចំណុចទី២ ដកហូតផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬប័ណ្ណផ្សព្វផ្សាយផលិតផលថ្នាំជក់ផ្សេងៗទៀត។ ការមិនអនុវត្តតាមជំហ៊ាននីតិវិធីច្បាប់ និងដាក់ពាក្យបណ្តឹង ដោយមិនទទួលការស្នើសុំណាត់ជួបជាមួយក្រុមហ៊ុនកូនក្តីយើងខ្ញុំ គឺការមិនផ្តល់ឱកាសដល់កូនក្តីរបស់យើងខ្ញុំក្នុងការស្វែងយល់ពីកំហុសឆ្គងដោយអចេតនា និងដើម្បីទទួលយកនូវដំបូន្មានពីក្រសួងដែលជាអាណាព្យាបាល។

ធាតុផ្សំនៃបទល្មើស: ធាតុអត្តនោម័ត ក្រុមហ៊ុនបានដំណើរការជាប់ជាប្រចាំ កំឡុងពេល ០៣ (បី) ទស្សវត្សនេះ ពុំដែលមានចេតនាទុច្ចរិតណាមួយ ហើយក៏មិនមានចេតនាក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម ផលិតផលថ្នាំជក់ដោយអនុវត្តឲ្យខុសនឹងវិធានសុខាភិបាលនោះទេ។ បើករណីក្រសួងសុខាភិបាលយល់ឃើញថាមានកំហុស គួរណាផ្ញើលិខិតផ្ទាល់អំពីការណែនាំ និងការកែតម្រូវជាអាទិ៍។ ធាតុសត្យានុម័ត រូបភាពចំនួន ០៤ទំព័រ ត្រូវបានប្រមូលដកហូតមកវិញ និងផ្អាកការចេញបន្តចែកចាយតាំងពីខែកុម្ភៈ ឆ្នាំ២០២១ មកម្ល៉េះ។ ហេតុដូច្នេះ ពុំទាន់មានធាតុផ្សំគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋានច្បាស់លាស់សម្រាប់ជូនអង្គសវនាការ ធ្វើការសម្រាប់ពិន័យលើក្រុមហ៊ុនកូនក្តីយើងខ្ញុំឡើយ។

**សន្និដ្ឋានលើអាទិភាពរបស់កូនក្តី**

សរុបសេចក្តីមក ក្រសួងសុខាភិបាលពុំបានអនុវត្តនីតិវិធីរបស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ ឬគ្រប់ជំហ៊ាន ស្របតាមមាត្រា ១០ នៃអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ នោះទេ ហើយក៏ពុំបានអនុវត្តទទួលការស្នើសុំជួប សុំការទូន្មាន និងកែតម្រូវឲ្យបានត្រឹមត្រូវផងដែរ ទាំងនេះជាការចូលរួមកំហុសរបស់ក្រសួងសុខាភិបាល ក្នុងនាមជាអាណាព្យាបាលលើក្រុមហ៊ុនកូនក្តីយើងខ្ញុំដែលតែងតែទទួលយកនូវការណែនាំពីក្រសួងសុខាភិបាល។ ដូចនេះយើងខ្ញុំសំណូមពរសុំឲ្យចៅក្រមជំនុំជម្រះ សម្រេចលើកលែងចោទប្រកាន់លើកូនក្តីយើងខ្ញុំ។

-ជនជាប់ចោទឈ្មោះ គង់ ហេង និយាយសំដីចុងក្រោយថា៖សុំឲ្យតុលាការលើកលែងចោទប្រកាន់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានពាក្យបណ្តឹងរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤៧ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ មកជំនុំជម្រះដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ០៥៨ អ.ឃ.ឃ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ គង់ ហេង ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន VINITON GROUP CO.,LTD មកជំនុំជម្រះពីបទផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពី

អំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩ , មាត្រា ១០ ,មាត្រា ១១ ,មាត្រា ៣៩ ,មាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ **គង់ ហេង** បានឆ្លើយថា: ពាក់ព័ន្ធនឹងរូបភាពដែលលោកស្រីចៅក្រមបង្ហាញនេះ ដូចហេតុផលដែលខ្ញុំបានជម្រាបអញ្ចើង រូបនេះគឺក្រុមហ៊ុនបានចែកចាយជាយូរណាស់មកហើយ ហើយក្រុមហ៊ុនកំពុងតែដើរប្រមូលយករូបនេះទាំងអស់នេះមកវិញ ដើម្បីធ្វើការបំផ្លាញចោល តែវានៅសល់ខ្លះៗនៅលើទីផ្សារ តែក្រុមហ៊ុនក៏ព្យាយាមប្រមូលយកមកទាំងអស់។ កន្លងមកក្រុមហ៊ុនបានព្យាយាមសុំជួបខាងក្រសួងសុខាភិបាល ដើម្បីសូមទោសពីកំហុសទាំងនេះ និងសូមធ្វើការណែនាំ ប៉ុន្តែខាងក្រសួងមិនព្រមឲ្យជួបនោះទេ។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ខាងក្រុមហ៊ុនបានជួបជាមួយក្រសួងសេដ្ឋកិច្ច និងក្រសួងសុខាភិបាល និងបានបកប្រាយជូនក្រសួងសុខាភិបាលពាក់ព័ន្ធនឹងរូបភាពដែលក្រុមហ៊ុនបានចែកចាយជាយូរមកហើយនោះ។ ក្រុមហ៊ុន VINITON មានបារីច្រើនប្រភេទ ប៉ុន្តែមានបារីខ្លះយើងបានចរាចរ ហើយបារីខ្លះមិនទាន់បានចរាចរទេ ចំពោះបារីដែលចរាចរណ៍លើកទីផ្សារនៅកម្ពុជាមានប្រាំប្រភេទ មានបារីក្រោន បារីអង្គរបារីខេមបូ បារីលុច សារី និងបារីអង្គរលុចសារី។ ក្រោយពេលទទួលបានដំណឹងពីក្រសួងសុខាភិបាលមក ក្រុមហ៊ុនបានព្យាយាមសុំជួបខាងក្រសួងខាភិបាល និងបានពន្យល់អំពីរឿងហេតុនេះ ប៉ុន្តែខាងក្រសួងព្រមឲ្យជួបនោះទេ ហើយក៏មិនឃើញមានការឆ្លើយតបអ្វីពីក្រសួងដែរ។ ខ្ញុំសូមបញ្ជាក់ថា ក្រោយពីទទួលដំណឹងពីខាងក្រសួងសុខាភិបាលពីករណីរឿងរូបភាពនេះ ខាងក្រុមហ៊ុនបានព្យាយាមប្រមូលយករូបភាពទាំងអស់មកវិញ ប៉ុន្តែជាធម្មតាយើងមិនអាចប្រមូលបានយកមកវិញទាំងអស់ទេ ប៉ុន្តែកន្លងមកមានអាជ្ញាធរបានធ្វើការណែនាំរួចហើយ។ តាំងពីពេលកើតហេតុមក ក្រុមហ៊ុនមិនបានចេតនាក្នុងការផ្សព្វផ្សាយទៀតទេ។ ក្រុមហ៊ុនមិនដែលបានទទួលលិខិតព្រមានជាលាយល័ក្ខណ៍អក្សរពីខាងក្រសួងនោះទេ ប៉ុន្តែក្រុមហ៊ុនទទួលបានព័ត៌មានខ្លះៗដែរ។ មុនពេលដែលបារីដាក់លក់លើទីផ្សារ ខាងក្រុមហ៊ុនមានគណៈកម្មការមួយដែលមានសមាជិកពី០៦ ទៅ១២នាក់ មានសមាជិកក្រុមហ៊ុនប្រឹក្សាភិបាល និងផ្នែកទីផ្សារ ដែលប្រធានគណៈកម្មការមានតួនាទីជាប្រធានក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យ។

៣-តាមអំណានពាក្យបណ្តឹងរបស់ក្រសួងសុខាភិបាល ដែលតំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ឹង ភីរុន** ជារដ្ឋលេខាធិការក្រសួងសុខាភិបាល បានបញ្ជាក់ថា: កន្លងមកក្រុមហ៊ុន VINITON Group Co,Ltd ដែលជាក្រុមហ៊ុនលក់ផលិតផលថ្នាំជក់ បានធ្វើការផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួននៅទីសាធារណៈជាលក្ខណៈផ្ទាំងគំនូរ និងប័ណ្ណផ្សព្វផ្សាយ ហើយក្នុងនោះក្រុមហ៊ុននេះបានប្រើប្រាស់ពាក្យទាក់ទាញ និងធ្វើឲ្យយល់ច្រលំដូចជាពាក្យថា ដើមតូច គ្រាប់តូច រស់ជាតិផ្អែឈើ ក្លិនក្រអូប ស្រទន់ជាដើម ដូចមានបញ្ជាក់ក្នុងរូបភាពដែលភ្ជាប់ជាមួយភស្តុតាង។ ក្រសួងសុខាភិបាលក៏បានធ្វើការព្រមានក្រុមហ៊ុននេះរួចហើយដែរ អំពីសកម្មភាពខាងលើ ព្រោះថាវាជាសកម្មភាពខុសច្បាប់ ប៉ុន្តែក្រុមហ៊ុននេះនៅតែមិនគោរពតាមច្បាប់ និងការព្រមានរបស់ក្រសួងសុខាភិបាលទៀត។ យោងតាមសកម្មភាពខាងលើ គឺក្រុមហ៊ុននេះបានបំពាននូវច្បាប់ស្តីពីការត្រួតពិនិត្យ

ផលិតផលថ្នាំជក់ ហើយការផ្សព្វផ្សាយបែបនេះអាចជម្រុញឱ្យមានការប្រើប្រាស់ថ្នាំជក់កាន់តែច្រើន និងអាចនាំឱ្យមានផលប៉ះពាល់ដល់សុខភាពប្រជាជន និងសុខភាពសាធារណៈដែលច្បាប់ព្យាយាមការពារ ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ **គង់ ហេង** ,អំណានពាក្យបណ្តឹងរបស់ក្រសួងសុខាភិបាល និងភស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា ក្រុមហ៊ុន VINITON Group Co,Ltd និងឈ្មោះ **គង់ ហេង** ដែលជាអនុប្រធានគ្រប់គ្រងផ្នែកទីផ្សាររបស់ក្រុមហ៊ុន VINITON Group Co,Ltd បានធ្វើសកម្មភាពផ្សព្វផ្សាយផលិតបារីដោយប្រើពាក្យទាក់ទាញ និងធ្វើឱ្យមានការយល់ច្រលំដូចជាពាក្យថា ដើមតូច គ្រាប់តូច រស់ជាតិផ្លែឈើ ក្លិនក្រអូប ស្រទន់ ដោយមិនមានការអនុញ្ញាតពីក្រសួងសុខាភិបាល ពិតប្រាកដមែន។

៥-អំពើរបស់ជនជាប់ចោទឈ្មោះ **គង់ ហេង** ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន VINITON Group Co,Ltd ដែលបានធ្វើសកម្មភាពផ្សព្វផ្សាយផលិតផលបារីដោយប្រើពាក្យទាក់ទាញដូចជាដើមតូច គ្រាប់តូច រស់ជាតិផ្លែឈើ ក្លិនក្រអូប ស្រទន់ ដោយមិនមានការអនុញ្ញាតពីក្រសួងសុខាភិបាល គឺជាបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល**។

៦-ជនជាប់ចោទឈ្មោះ **គង់ ហេង** ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន VINITON Group Co,Ltd ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តជននេះមានសមត្ថភាព លទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ **គង់ ហេង** ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន VINITON Group Co,Ltd បានបង្ហាញឱ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទរូបនេះមានចេតនាទុច្ចរិត ដែលការប្រព្រឹត្តទាំងនេះធ្វើអោយប៉ះពាល់ដល់សន្តិសុខសង្គម សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា ៩ ,មាត្រា ១០ ,មាត្រា ១១ ,មាត្រា ៣៩ ,មាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

៨-មានភស្តុតាង និងមានពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ **គង់ ហេង** ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន VINITON Group Co,Ltd ពីបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩ ,មាត្រា ១០ ,មាត្រា ១១ ,មាត្រា ៣៩ , មាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

៩-ជនជាប់ចោទឈ្មោះ គង់ ហេង ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ តាមជីវប្រវត្តិកន្លងមកជនជាប់ចោទរូបនេះមិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។

១០-ដើមបណ្តឹងរដ្ឋប្បវេណីក្រសួងសុខាភិបាល ដែលតំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ឹង ភីរុន** ជារដ្ឋលេខាធិការក្រសួងសុខាភិបាល បានទាមទារសំណងចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល) គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១១-ព្យសនកម្មដែលកើតឡើងដោយសារអំពើរបស់ជនជាប់ចោទឈ្មោះ **គង់ ហេង** និងក្រុមហ៊ុន VINITON Group Co,Ltd ដូច្នេះជនជាប់ចោទរូបនេះទទួលខុសត្រូវទាំងស្រុងចំពោះការជួសជុលសំណងទៅតាមកំរិត និងព្យសនកម្មដែលកើតឡើង។

១២-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ គប្បីតុលាការលើកយកមកពិចារណា។

១៣-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានភស្តុតាងគ្រប់គ្រាន់អាចឲ្យតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្តី។

១៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សុំឲ្យតុលាការលើកលែងចោទប្រកាន់លើកូនក្តីខ្លួន ពុំមានភស្តុតាងគ្រប់គ្រាន់អាចឲ្យតុលាការលើកយកមកពិចារណាបានទេ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើឈ្មោះ **គង់ ហេង** ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន VINITON Group Co,Ltd ពិន័យជាប្រាក់ចំនួន ៣០,០០០,០០០៛ (សាមសិបលានរៀល) រៀល ពីបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩ ,មាត្រា ១០ ,មាត្រា ១១ ,មាត្រា ៣៩ ,មាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ **គង់ ហេង** និងក្រុមហ៊ុន VINITON Group Co,Ltd សងសំណងជំងឺចិត្តឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០,០០០,០០០៛ (ម្ភៃលានរៀល) ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ គង់ ហេង និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: **ឈិន ឆេង**

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: **ទិត ដាលីន**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម" ។

ថ្ងៃច័ន្ទ ១១ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២

បានឃើញ
**ចៅក្រមជំនុំជម្រះ**

**ទិត ដាលីន**

**ក្រឡាបញ្ជីសវនាការ**

**ឈិន ឆេង**